ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៣ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍ នៅមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ដល់ថ្នាក់ទី១២

**យោង៖** ស្មារតីអង្គប្រជុំថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបញ្ចូលការសរសេរតាមអាន ទៅក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ថ្នាក់ទី៩ និងការបញ្ចូលសិក្សាអត្ថបទរឿងទាំងមូលពីថ្នាក់ទី៧ រហូតដល់ថ្នាក់ទី១២ សម្រាប់ឆ្នាំសិក្សា២០១៥-២០១៦។

ការសិក្សាវិភាគរឿងទាំងមូលមានសារៈសំខាន់ណាស់ ក្នុងការសិក្សាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ព្រោះវាធ្វើឱ្យអ្នកសិក្សាយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅទៅលើអត្ថន័យ(ខ្លឹមសារ) អត្ថរូប(វិធីតែងនិពន្ធ) និងអត្ថរស(គុណតម្លៃ)នៃរឿងនីមួយៗ ព្រមទាំងធ្វើឱ្យអ្នកសិក្សា យល់ដឹងបន្ថែមទៀត ពីជីវប្រវត្តិ ស្នាដៃសំខាន់ៗ សង្គមបរិយាកាសនៃការកកើតរឿង និងទស្សនវិស័យរបស់អ្នកនិពន្ធ។ ម្យ៉ាងទៀត ការសរសេរតែងសេចក្តីបែបអត្ថាធិប្បាយបានល្អត្រឹមត្រូវ ច្បាស់លាស់ ក្បោះក្បាយ និងស៊ីជម្រៅ លុះត្រាតែអ្នកសិក្សាយល់ដឹងច្បាស់លាស់ទូលំទូលាយ ទៅលើខ្លឹមសារនៃរឿងទាំងមូល រួមផ្សំនឹងចំណេះដឹងទូទៅបន្ថែមទៀត។

ដូច្នេះដើម្បីឱ្យការរៀន និងបង្រៀនវិភាគរឿងទាំងមូលនៅក្នុងមុខវិជ្ជាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ នៅមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅ៖

### ១.រឿងដែលត្រូវវិភាគ

ខ្លឹមសាររឿងខាងក្រោម មានជាអត្ថបទដកស្រង់ ឬជាសាច់រឿងទាំងមូលស្រាប់ នៅក្នុងមេរៀននៃសៀវភៅសិក្សាគោលដែលកំពុងសិក្សាសព្វថ្ងៃ។ ប៉ុន្តែមិនបានសិក្សាវិភាគរឿងទាំងមូលនៅឡើយទេ គឺមានតែការសិក្សាអត្ថបទដកស្រង់ប៉ុណ្ណោះ។ ខាងក្រោមនេះជារឿងដែលត្រូវវិភាគតាមថ្នាក់នីមួយៗ៖

- ថ្នាក់ទី១០ រឿង ទុំទាវ
- ថ្នាក់ទី១១ រឿង ព្រះវេស្សន្តរ (ថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម)
- ថ្នាក់ទី១២ រឿង រាមកេរ្តិ៍ (ថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម)

### ២.គម្រោងទូទៅនៃការសិក្សាអត្ថបទ

ក្នុងការវិភាគអត្ថបទរឿងនីមួយៗ ត្រូវវិភាគរកឱ្យឃើញនូវចំណុចធំៗ និងអនុលោមតាមគម្រោងរួមដូចខាងក្រោមនេះ៖



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

I.ការបង្ហាញអត្ថបទ

១.អត្ថបទ

- ចំណងជើង
- ប្រភព
- ប្រភេទ (រឿងនិទាន បុរាណ ទំនើប ល្ខោន ... )
- ចលនា (ព្រាហ្មណ៍និយម ពុទ្ធនិយម ខេមរនិយម បរទេសនិយម )

២.អ្នកនិពន្ធ

- ឈ្មោះអ្នកនិពន្ធ
- ជីវប្រវត្តិ
- ស្នាដៃសំខាន់ៗ

៣.កាលកំណត់តែង

- ថ្ងៃ ខែ ឆ្នាំ នៃការតាក់តែង
- ថ្ងៃ ខែ ឆ្នាំ នៃការបោះពុម្ព

៤.សង្គមបរិយាកាស

- កាលប្រវត្តិ (សម័យកាលកកើតរឿង)
- ព្រឹត្តិការណ៍សំខាន់ៗ

II.ការវិភាគអត្ថបទ

ក.ស្ថានភាពរឿង

- សង្ខេបរឿង
- តួអង្គ (តួអង្គឯក តួអង្គរង តួអង្គបន្ទាប់បន្សំ តួអង្គរំឭក )
- កាលអាកាស
- ព្រឹត្តិការណ៍សំខាន់ៗ ឬបញ្ហាសង្គមដែលបង្ហាញ... ។

ខ.អត្ថន័យ

- ប្រធានរឿង
- មូលបញ្ហារឿង
- ទំនាស់
- វិភាគតួអង្គ (គុណសម្បត្តិ គុណវិបត្តិ )
- ឧត្តមគតិរឿង ។

គ.អត្ថរូប

- វិធីតែងនិពន្ធ (ពាក្យរាយ ពាក្យកាព្យ កម្រងកែវ ល្ខោន និងការប្រើប្រាស់ភាសា... )
- ការផ្ដើមរឿង (បង្ហាញតួអង្គ រៀបរាប់ទេសភាព នមស្សការព្រះរតនត្រៃ ហោមពិធី... )
- ដំណើររឿង (ពណ៌នាដំណើររឿងដោយនិទានវិធី សំវាទវិធី ឯកវាទវិធី សន្ទេហវិធី... )
- ការបញ្ចប់រឿង (សង្ឃឹមគឺ ជួបជុំទទួលជោគជ័យ អស់សង្ឃឹមគឺ បែកបាក់ព្រាត់ប្រាស...)។

ឃ.អត្ថរស

- កុសលរស
- សង្គមរស
- គជរស
- វីររស

- អច្ឆរិយរស
- ហាស្សរស
- ការុណរស
- នាដករស ...... ។ល។

ង.បញ្ហាសង្គម

១.នយោបាយ

- ក្នុងប្រទេស (អ្នកគ្រប់គ្រង របបគ្រប់គ្រង ...)
- ក្រៅប្រទេស (ទំនាក់ទំនងអន្តរជាតិ ... ) ។

២.សេដ្ឋកិច្ច

- កសិកម្ម
- ផលិតកម្ម សិប្បកម្ម
- ឧស្សាហកម្ម
- ពាណិជ្ជកម្ម
- គមនាគមន៍
- ទេសចរណ៍

៣.សង្គមកិច្ច

- ស្ថានភាពរស់នៅ
- សុខាភិបាល
- មុខរបរនិងជីវភាព របស់ប្រជាជន ... ។

៤.វប្បធម៌

- ជំនឿ ប្រពៃណី ទំនៀមទម្លាប់
- សាសនា
- ការសិក្សាអប់រំ
- សិល្បៈ
- ។ល។

III.ការសន្និដ្ឋាន

**៣.ទីតាំងនិងលំដាប់លំដោយក្នុងការបង្រៀន**

ការបង្រៀនវិភាគអត្ថបទរឿងទាំងមូលនេះ មិនប៉ះពាល់ដល់លំដាប់លំដោយខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលឡើយ។ លោកគ្រូ អ្នកគ្រូ នៅតែបង្រៀនទៅតាមលំដាប់លំដោយមេរៀន ដែលមានស្រាប់ក្នុងសៀវភៅដដែល ព្រោះរឿងដែលលើកយកមកសិក្សាវិភាគទាំងមូលនេះនៅក្នុងសៀវភៅសិក្សាគោលសព្វថ្ងៃ រឿងមួយចំនួនជាអត្ថបទដកស្រង់តែប៉ុណ្ណោះ។ អ្នកជំនាញនឹងដកចេញនូវខ្លឹមសារដែលមានស្រាប់មិនពេញលេញ ឬស្ទួនហើយដាក់ជំនួសដោយការវិភាគរឿងទាំងមូលវិញ។ ខាងក្រោមនេះ ជាទីតាំងដែលត្រូវដាក់បញ្ចូលការវិភាគរឿងទាំងមូលតាមថ្នាក់នីមួយៗ ៖

| | | | |
|---|---|---|---|
| - ថ្នាក់ទី១០ | រឿង ទុំទាវ | ក្នុងមេរៀនទី ៥ | |
| - ថ្នាក់ទី១១ | រឿង ព្រះវេស្សន្តរ | ក្នុងមេរៀនទី ៣ | (វិទ្យាសាស្ត្រ និងវិ.សង្គម) |
| - ថ្នាក់ទី១២ | រឿង រាមកេរ្តិ៍ | ក្នុងមេរៀនទី ២ | (វិទ្យាសាស្ត្រ និងវិ.សង្គម) |

(លម្អិតសូមមើលក្នុងឧបសម្ព័ន្ធ)

៤.ការប្រើប្រាស់ម៉ោង

ការបង្រៀនវិភាគអត្ថបទរឿងទាំងមូល ត្រូវប្រើប្រាស់ម៉ោងសិក្សា ដែលបានកំណត់ក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ភាសាខ្មែរ ដែលមានចែងច្បាស់លាស់ក្នុងកាលវិភាគប្រចាំសប្តាហ៍។ ការបង្រៀននេះត្រូវបង្រៀនទៅតាមលំដាប់លំដោយខ្លឹមសារ និងម៉ោងពេលជាធម្មតា លុះមកដល់ការសិក្សាវិភាគអត្ថបទរឿងទាំងមូល គ្រូគប្បីប្រើប្រាស់ម៉ោងទៅតាមការបែងចែក ទៅតាមថ្នាក់ មេរៀន និងម៉ោងដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ថ្នាក់ទី១០ | រឿង ទុំទាវ | (ក្នុងមេរៀនទី៥ រយៈពេល ៤០ម៉ោង) |
| ២.ថ្នាក់ទី១១ | រឿង រឿងព្រះវេស្សន្តរ | (ថ្នាក់វិ.សាស្ត្រ ក្នុងមេរៀនទី៣ រយៈពេល ៣៦ម៉ោង) |
| | | (ថ្នាក់វិ.សង្គម ក្នុងមេរៀនទី៣ រយៈពេល ៤២ម៉ោង) |
| ៣.ថ្នាក់ទី១២ | រឿង រាមកេរ្តិ៍ | (ថ្នាក់វិ.សាស្ត្រ ក្នុងមេរៀនទី២ រយៈពេល ៣៦ម៉ោង) |
| | | (ថ្នាក់វិ.សង្គម ក្នុងមេរៀនទី២ រយៈពេល ៤២ម៉ោង) |

(លម្អិតសូមមើលក្នុងឧបសម្ព័ន្ធ)

❖កំណត់សម្គាល់ ៖ ចំពោះរឿងដទៃទៀតដែលមានក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលកំពុងបង្រៀន តាមថ្នាក់នីមួយៗលោកគ្រូ អ្នកគ្រូអាចលើកយកមកសិក្សាវិភាគរឿងទាំងមូលបន្ថែមទៅតាមគម្រោងរួមក្នុង ចំណុច២ខាងលើទៅតាមពេលវេលា និងលទ្ធភាពជាក់ស្តែង ។

ទទួលបានសេចក្តីណែនាំនេះសូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្តទាំងអស់ ចាត់ចែងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាលារៀនមធ្យមសិក្សាទុតិយភូមិក្រោមឱវាទនិងចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ៣ ឆ្នាំ ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គនាយកដ្ឋានអប់រំ
- នាយកដ្ឋានពាក់ព័ន្ធ

" ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់មន្ទីរអយក.រាជធានី-ខេត្ត
- ការិយាល័យអយក.ស្រុក-ខណ្ឌ
- គ្រប់សាលាមធ្យមសិក្សាទុតិយភូមិ

" ដើម្បីអនុវត្ត "
- កាលប្បវត្តិ- ឯកសារ.អកស.